ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍

សមាជិកព្រឹទ្ធសភា គណបក្ស សម រង្ស៊ី ទាំង ១១រូប សូមគាំទ្រទាំងស្រុងនូវសេចក្តីថ្លែងការណ៍របស់គណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការរំលោភរដ្ឋធម្មនុញ្ញ ដែលការប្រជុំដំបូងរបស់ក្រុមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានរៀបចំថ្នាក់ដឹកនាំរដ្ឋសភា និងគណៈរដ្ឋមន្ត្រីនីតិកាលទី៥ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣។

សមាជិកព្រឹទ្ធសភាគណបក្សសមរង្ស៊ីយល់ឃើញថារបស់ដែលគេហៅថាការប្រជុំដំបូងដោយពុំមានការចូលរួមពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ តែបានយកច្បាប់ធម្មនុញ្ញបន្ថែមមកអនុវត្តនោះគឺឆ្លុះបញ្ចាំងថាគណបក្សប្រជាជនកម្ពុជាគ្មានសម្លេងគ្រប់តែឯកឯង ដើម្បីរៀបចំថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល ដូចដែលគណបក្សសង្គ្រោះជាតិ កំពុងទាមទារឲ្យមានគណៈកម្មការចម្រុះឯករាជ្យ ស៊ើបអង្កេតរកគណបក្សដែលឈ្នះក្នុងការបោះឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ពិតប្រាកដសិន មុនបើកការប្រជុំដំបូងរបស់រដ្ឋសភា។

ការបើកអង្គប្រជុំដំបូង និងការរៀបចំរដ្ឋសភា រដ្ឋាភិបាល ដោយរំលោភរដ្ឋធម្មនុញ្ញនេះ មិនអាចឲ្យមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ទទួលស្គាល់នោះទេ។ ការអបអរ ឬការទទួលស្គាល់ការប្រជុំដំបូង និងលទ្ធផលប្រជុំដំបូង គឺជាការចូលរួមរំលោភរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។

សមាជិកព្រឹទ្ធសភា គណបក្ស សម រង្ស៊ី ទាំង ១១រូប មិនទទួលស្គាល់រដ្ឋសភា និងរាជរដ្ឋាភិបាលនីតិកាលទី៥ ដែលកើតចេញពីការរំលោភរដ្ឋធម្មនុញ្ញ របស់ព្រះរាជាណាចក្រកម្ពុជានេះឡើយ៕

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣

**ហត្ថលេខាសមាជិកព្រឹទ្ធសភា គណបក្ស សម រង្ស៊ី**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh